សម្រាប់ការចេញផ្សាយភ្លាមៗ

# វេទិកាសាធារណៈរបស់គណៈកម្មការទន្លេមេគង្គ នឹងពិភាក្សាពីបញ្ហាប្រឈមនានាលើការអភិវឌ្ឍ ដើម្បីស្វែងរកដំណោះស្រាយរួមគ្នា

**ទីក្រុងវៀងចន្ទ ប្រទេសឡាវ ថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ២០២២** – ក្នុងពេលឆាប់ៗនេះ គណៈកម្មការទន្លេមេគង្គ (ហៅកាត់ថា MRC) នឹងរៀបចំវេទិកាភាគីពាក់ព័ន្ធប្រចាំតំបន់លើកទី១៣ របស់ខ្លួន ដែលពេលនោះ MRC មិនត្រឹមតែផ្តល់ព័ត៌មានបច្ចុប្បន្នភាពពីគម្រោងទំនប់វារីអគ្គិសនីតាមដងទន្លេធំបំផុតប្រចាំតំបន់អាស៊ីអាគ្នេយ៍ប៉ុណ្ណោះទេ គេក៏បង្ហាញជាពិសេសពីកិច្ចសហប្រតិបត្តិការដ៏ស៊ីជម្រៅជាមួយនឹងសកម្មជន ដែលតំណាងឲ្យប្រយោជន៍នៃក្រុមគ្រួសារនេសាទ និងកសិកររាប់លាននាក់ក្នុងតំបន់ទន្លេមេគង្គនេះផងដែរ។

វេទិកាចាប់ពី១២ ដល់១៣ ធ្នូ នឹងប្រារព្ធឡើងក្នុងទីក្រុងហូជីមិញ ប្រទេសវៀតណាម ហើយនឹងត្រូវផ្សាយបន្តផ្ទាល់ក្នុងពេលតែមួយតាមប្រព័ន្ធអនឡាញ។ វេទិការយៈពេលមួយថ្ងៃកន្លះនេះ នឹងបើកបង្ហាញនូវបញ្ហាប្រឈមជាច្រើន ដែលអាងទន្លេកំពុងជួបប្រទះ ក៏ដូចជាដំណោះស្រាយដែលបានស្នើផងដែរ ក្នុងនោះរួមមានការធ្វើឲ្យមានតុល្យភាពរវាងកំណើនសេដ្ឋកិច្ចពីការអភិវឌ្ឍន៍ធនធានទឹក រហូតដល់ការកាត់បន្ថយផលប៉ះពាល់នានាឲ្យដល់កម្រិតទាបបំផុតលើប្រព័ន្ធអេកូឡូស៊ី ឬសហគមន៍តាមដងទន្លេ និងការគ្រប់គ្រងការខូចខាតបណ្តាលមកពីកត្តាមនុស្ស និងការប្រែប្រួលអាកាសធាតុ។

ខណៈដែលអ្នកចូលរួម នឹងទទួលបានព័ត៌មានបច្ចុប្បន្នភាពពីទំនប់វារីអគ្គិសនីមួយចំនួនតាមដងទន្លេមេគង្គ គេក៏មានឱកាសចែករំលែកពីទស្សនៈ ការព្រួយបារម្ភ និងមតិយោបល់ផ្សេងៗរបស់គេផងដែរ។ បន្ថែមពីនេះ អង្គការសង្គមស៊ីវិល (CSOs) កំពុងរៀបចំរបៀបវារៈរួមគ្នាសម្រាប់ថ្ងៃទីពីរនៃវេទិកា ដែលនេះជាសញ្ញាមួយនៃកំណើនក្នុងការចូលរួមផ្តល់មតិយោបល់ ក្នុងការរៀបចំអាទិភាពរបស់ MRC។ វាក៏បានឆ្លុះបញ្ចាំងពីគោលបំណងរបស់ MRC ក្នុងការស្នើសុំមតិកែលម្អដែលអាចមាន និងការចូលរួមយ៉ាងស៊ីជម្រៅជាមួយនឹង CSOs។ នេះបើយោងតាមប្រសាសន៍របស់បណ្ឌិត អានុល័ក ខិធិឃួន នាយកប្រតិបត្តិនៃលេខាធិការដ្ឋាន MRC។

បណ្ឌិត ខិធិឃួន ថ្លែងថា "អ្នកមិនអាចធ្វើអ្វីមួយឲ្យបានល្អប្រសើរតែម្នាក់ឯងបានទេ ប៉ុន្តែយើងអាចប្រសិនបើយើងធ្វើរួមគ្នា។ ទន្លេមេគង្គជាកម្មសិទ្ធរបស់ពលរដ្ឋគ្រប់គ្នា ដូច្នេះយើងមានទំនួលខុសត្រូវរួម មិនត្រឹមតែលើការអភិវឌ្ឍទន្លេនេះទេ ប៉ុន្តែថែមទាំងគាំពារវាទៀតផង"។

នៅក្រោមប្រធានបទ "ការបង្កើតដំណោះស្រាយរួមគ្នា សម្រាប់សុខភាពអាងទន្លេមេគង្គ" វេទិកានេះតំណាងឲ្យផ្នែកមួយនៃបេសកកម្មរបស់ MRC ដែលជាស្ថាប័នអន្តររដ្ឋាភិបាល រួមមានប្រទេសកម្ពុជា ឡាវ

ថៃ និងវៀតណាម មានតួនាទីជា “មជ្ឈមណ្ឌលចំណេះដឹង” ប្រកបដោយតម្លាភាពមួយ និងវេទិកាសម្របសម្រួល “ការទូតទឹក”មួយ។

ក្រៅពីមន្ត្រី MRC និងតំណាងរដ្ឋាភិបាល ដែលនឹងចូលរួមវេទិកាលើកទី១៣ នេះ អ្នកចូលរួមផ្សេងទៀត រួមមានអ្នកអភិវឌ្ឍន៍គម្រោងទំនប់វារីអគ្គិសនី ដៃគូអន្តរជាតិ អ្នកស្រាវជ្រាវ សកម្មជនមិនមែនរដ្ឋាភិបាល និងតំណាងសហគមន៍តាមដងទន្លេមេគង្គ។

ខណៈដែលកាលពីមុន គេមើលឃើញ MRC ជា “ភាគីប្រឆាំង” ថ្មីៗនេះ MRC បានខិតខំបង្កើតនូវវេទិកាជាច្រើន សម្រាប់ការយល់ដឹងរួម ការចូលរួមពីភាគីពាក់ព័ន្ធ និងដើម្បីពង្រីកមតិយោបល់ផ្សេងគ្នាៗ លើវិស័យនេះទាំងមូល។

បណ្ឌិត ខិធិឃួន បន្តទៀតថា “ខ្ញុំរីករាយនឹងបង្កើតឲ្យបានកាន់តែច្រើននូវលំហសម្រាប់ការចូលរួមកាន់តែស៊ីជម្រៅ។ យើងទទួលស្គាល់ពីតម្រូវការក្នុងការកសាងភាពជឿជាក់ និងទំនុកចិត្ត ព្រោះថាអ្នកមិនអាចធ្វើការរួមគ្នា ដោយគ្មានទំនុកចិត្ត និងការយល់ដឹងពីបញ្ហាប្រឈមនានា ដែលភាគីនីមួយៗជួបប្រទះនោះទេ។ ដូច្នេះ យើងត្រូវធ្វើការរួមគ្នា ស្វែងរកដំណោះស្រាយសម្រាប់បញ្ហាប្រឈមទាំងនេះ ដើម្បីទន្លេតែមួយគត់របស់យើង”។

នៅក្នុងចំណោមរបៀបវារៈសំខាន់ៗ សិក្ខាកាមនឹងទទួលបានព័ត៌មានពីរបកគំហើញដំបូងខ្លះៗនៃការសិក្សាស្រាវជ្រាវរួមដ៏សំខាន់ រវាង MRC និងមជ្ឈមណ្ឌលទឹកស្តីពីកិច្ចសហប្រតិបត្តិការឡានឆាង-មេគង្គ ដែលតំណាងឲ្យប្រទេសតាមដងទន្លេឡាងឆាង-មេគង្គទាំង៦។ ការសិក្សានេះ បានបង្ហាញនៅវេទិកាភាគីពាក់ព័ន្ធប្រចាំតំបន់លើកទី១២ កាលពីខែមិថុនា ដែលមានគោលបំណងស្វែងយល់ពីការប្រែប្រួលរបបរំហូរទឹក បង្កដោយអាកាសធាតុ និងការអភិវឌ្ឍ, បង្កើនការចែករំលែកព័ត៌មានពីផលប៉ះពាល់នៃប្រតិបត្តិការអាងស្តុកលើរំហូរទឹកទន្លេមេគង្គ ការបញ្ចេញទឹក និងគុណភាពទឹក, និងស្វែងរកដំណោះស្រាយដើម្បីកាត់បន្ថយ និងបន្សាំទៅនឹងផលប៉ះពាល់នានា។ ទិន្នន័យបែបនេះ ក៏បានដើរតួនាទីសម្រាប់ជូនពត័មានជាមុនដល់បណ្តាលប្រទេស និងសហគមន៍នៅផ្នែកខាងក្រោមទន្លេ ដើម្បីផ្តល់លទ្ធភាពឲ្យពួកគេរៀបចំផែនការទៅតាមការប្រែប្រួលនានា ឬទាញយកប្រយោជន៍ពីឱកាសណាមួយ។

របៀបវារៈផ្សេងទៀតដែលនឹងលើកយកមកបង្ហាញពិភាក្សាក្នុងអំឡុងពេលវេទិកា រួមមាន៖ ដំណើរការរបស់បណ្តាញតាមដានស្នូលសម្រាប់ទន្លេ ការគាំពារសុខភាពទន្លេមេគង្គ, បច្ចុប្បន្នភាពពីគម្រោងទំនប់វារីអគ្គិសនីមួយចំនួន រួមទាំងទំនប់ដនសាហុង សាណាខាំ សេកុងអា និងគម្រោងទំនប់ភូងយដែលបានស្នើ, របៀបដែលការអភិវឌ្ឍទំនប់វារីអគ្គិសនីជះឥទ្ធិពលលើដលផល និងការចិញ្ចឹមជីវិត រួមទាំងយន្តការកាត់បន្ថយផលប៉ះពាល់ ប្រភពផ្សេងៗនៃប្រាក់ចំណូល និងទម្រង់ផ្សេងទៀតនៃ “ការរស់នៅប្រកបដោយចីរភាព”, វិធីពង្រឹងភាពជាដៃគូរវាង MRC, CSOs និងវិស័យឯកជន។ ជាពិសេស វិធីធ្វើការសម្រេចចិត្តឲ្យកាន់តែមានបរិយាប័ន្ន សម្រាប់គម្រោងដែលលើកកម្ពស់ភាពចម្រុះ និងសមភាពយេនឌ័រ។

បេក្ខជនដែលចាប់អារម្មណ៍ អាចចុះឈ្មោះចូលរួមតាមប្រព័ន្ធអនឡាញនៅទីនេះ៖
https://forms.gle/EhD8FJJH1LbV7rLV7

ការចុះឈ្មោះចូលរួម បិទនៅថ្ងៃទី២ ខែធ្នូ។ ជំនួយហិរញ្ញវត្ថុតិចតួច មានសម្រាប់បេក្ខជនដាក់ពាក្យចូលរួម ដែលមានតម្រូវការជាក់ស្តែង។ អ្នកចូលរួម ក៏ត្រូវបានស្វាគមន៍ឲ្យទស្សនាការផ្សាយបន្តផ្ទាល់សម្រាប់វេទិកានេះ តាមបណ្តាញព័ត៌មានសង្គមណាមួយរបស់ MRC រួមមានហ្វេសបុក ធ្វីធឺរ លីនខអ៊ីន និងយូធូប។

**កំណត់សម្គាល់សម្រាប់និពន្ធនាយក៖**
គណៈកម្មការទន្លេមេគង្គ គឺជាស្ថាប័នអន្តររដ្ឋាភិបាល ដែលមានតួនាទីជំរុញលើកកម្ពស់កិច្ចពិគ្រោះយោបល់ និងកិច្ចសហប្រតិបត្តិការថ្នាក់តំបន់នៅក្នុងតំបន់អាងទន្លេមេគង្គខ្សែទឹកខាងក្រោម ដែលត្រូវបានបង្កើតឡើងក្នុងឆ្នាំ ១៩៩៥ ផ្អែកទៅតាមកិច្ចព្រមព្រៀងទន្លេមេគង្គ រវាងប្រទេសកម្ពុជា ឡាវ ថៃ និងវៀតណាម។ ស្ថាប័ននេះ បំពេញតួនាទីជាវេទិកាថ្នាក់តំបន់សម្រាប់ការទូតទឹក ក៏ដូចជាជាមជ្ឈមណ្ឌលប្រមូលផ្តុំចំណេះដឹងអំពីការគ្រប់គ្រងធនធានទឹក ដើម្បីអភិវឌ្ឍន៍តំបន់នេះប្រកបដោយចីរភាព។

**-ចប់-**

**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖**
លោក មាស សុភក្ត្រ មន្ត្រីជំនាញផ្នែកភាគីពាក់ព័ន្ធ
មន្ត្រីសារព័ត៌មានបណ្តោះអាសន្ន
លេខាធិការដ្ឋាននៃគណៈកម្មការទន្លេមេគង្គ
អ៊ីម៉ែល៖ sopheak@mrcmekong.org
ទូរស័ព្ទដៃ៖ +៨៥៦-២០-៧៧៧៧៩១៦៨

###